**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

លេខ :.......[illegible]............ប.ស្ត

# សេចក្តីប្រកាសព័ត៌មាន
## ការបង្កើតតំបន់ការពារធម្មជាតិចំនួន១៨ ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន

ក្រសួងបរិស្ថាន មានកិត្តិយសសូមជម្រាបជូនដល់សាធារណជន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ឱ្យបានជ្រាបថា នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**បានចុះហត្ថលេខាលើអនុក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិចំនួន ១៨ ដែលមានផ្ទៃដីសរុបចំនួន ២ ៦៧៤ ៥០៣ ហិកតាឱ្យស្ថិតក្រោមការគ្រប់គ្រង និងអភិរក្សរបស់ក្រសួងបរិស្ថាន។ តំបន់ព្រៃការពារ និងអភិរក្សព្រៃឈើចំនួន១៣ កន្លែង និងព្រៃផ្តល់ផលចំនួន ៥ កន្លែង ក្នុងនោះក៏មានព្រៃឡង់ផងដែរដែលត្រូវដាក់ជាតំបន់ការពារធម្មជាតិនេះទើបតែត្រូវបានរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចផ្ទេរពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមកឱ្យក្រសួងបរិស្ថានធ្វើការគ្រប់គ្រង និងអភិរក្ស។ ជារួម ក្រសួងបរិស្ថាន មានតំបន់ការពារធម្មជាតិសរុបចំនួន ៤១ ដែលមានផ្ទៃដីសរុបចំនួន ៥ ៨៧៤ ៥០៣ ហិកតា រួមបញ្ចូលទាំងតំបន់ការពារធម្មជាតិដែលក្រសួងបរិស្ថានមានស្រាប់តាំងពីឆ្នាំ១៩៩៣ មក ចំនួន២៣ ដែលមានផ្ទៃដីចំនួន ៣,២ លានហិកតា។

ដើម្បីគ្រប់គ្រងតំបន់ការពារធម្មជាតិទាំងនេះប្រកបដោយប្រសិទ្ធភាព ក្រសួងបរិស្ថាននឹងស្នើសុំការចុះបញ្ជីដីធ្លីលើតំបន់ការពារធម្មជាតិទាំងនេះ នៅក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ហើយក្រសួងបរិស្ថាន នឹងធ្វើការគ្រប់គ្រង និងអភិរក្សតំបន់ធនធានធម្មជាតិទាំងនេះ ដោយអនុវត្តតាមគោលការណ៍ស្បែកខ្លារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងដីធ្លី ដោយសារតែនៅក្នុងតំបន់ព្រៃការពារ និងអភិរក្សខ្លះ មានភូមិឋាន និងប្រជាជនកំពុងរស់នៅទីនោះ។ បន្ទាប់មក ក្រសួងបរិស្ថាននឹងធ្វើការសិក្សាវាយតម្លៃនិងរៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិឡើងវិញដើម្បីធានាដល់ប្រសិទ្ធភាពនៃកាគ្រប់គ្រង ការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី បន្ទាប់ពីការកាត់សម្បទានដីសេដ្ឋកិច្ចចេញពីតំបន់ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាននិងបានផ្ទេរទៅឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់គ្រងវិញ រួមនឹងការប្រាបាច់បញ្ចូលគ្នារវាងតំបន់ព្រៃការពារ និងអភិរក្សព្រៃឈើដែលផ្ទេរក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យក្រសួងបរិស្ថានគ្រប់គ្រង រួមបញ្ចូលជាមួយតំបន់ការពារធម្មជាតិរបស់ក្រសួងបរិស្ថានដែលមានស្រាប់។

រាជរដ្ឋាភិបាលកម្ពុជា ក្រសួងបរិស្ថានសូមថ្លែងអំណរគុណដល់ភាគីពាក់ព័ន្ធនានារួមមានសហគមន៍ព្រៃឡង់ និងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិធ្វើការងារលើការងារអភិរក្សព្រៃឈើ និងសត្វព្រៃដែលបានគាំទ្រចំពោះការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដាក់បញ្ចូលព្រៃផ្តល់ផលចំនួន ៥ កន្លែង រួមមានព្រៃឡង់ ព្រៃក្រវាញខាងត្បូង ព្រៃព្រះរកា ព្រៃសៀមប៉ាងខាងលិច និងព្រៃវីនសៃជាតំបន់ការពារធម្មជាតិថ្មីបន្ថែមទៀត និងបានត្រៀមខ្លួនរួចជាស្រេចដើម្បីសហការជាមួយរាជរដ្ឋាភិបាល និងក្រសួងបរិស្ថាន ស្ថាប័នផ្សេងទៀត តាមរយៈមធ្យោបាយផ្សេងៗដើម្បីធានាដល់ការងារអភិរក្សព្រៃឈើ ជីវៈចម្រុះដ៏មានតម្លៃ និងធនធានធម្មជាតិសំខាន់ៗដែលព្រះរាជាណាចក្រកម្ពុជាមានឱ្យបានគង់វង្សសម្រាប់មនុស្សជំនាន់នេះ និងជំនាន់ក្រោយៗទៀត។ នេះគឺជារបត់ប្រវត្តិសាស្ត្រថ្មីមួយដោយមានការចាប់ផ្តើមសន្ទនា និងសហការគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល រួមនឹងសហគមន៍ព្រៃឡង់ និងប្រជាពលរដ្ឋក្នុងការងារគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ ហើយនេះក៏ជាវប្បធម៌ថ្មីមួយទៀត ដើម្បីបម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជាលើវិស័យបរិស្ថាន។

ជាមួយគ្នានេះដែរ ក្រសួងបរិស្ថាន ក៏សូមអំពាវនាវដល់គ្រប់ភាគីទាំងអស់ជាពិសេសសហគមន៍នានា សង្គមស៊ីវិល ប្រជាពលរដ្ឋ រួមនឹងអាជ្ញាធរពាក់ព័ន្ធនានា ចូលរួមសហការគ្នាក្នុងការការពារធនធានធម្មជាតិ អភិរក្សជីវៈចម្រុះនានាស្របតាមច្បាប់ បទដ្ឋានគតិយុត្តដែលមានជាធរមានដើម្បីការពារធនធានធម្មជាតិយើងនៅគង់វង្សបានល្អ។ យើងចូលរួមការពារព្រៃឈើរបស់យើងទាំងអស់គ្នា!

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១៦

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង*
ឯកឧត្តម **សៅ សុភាព** នាយកខុទ្ទកាល័យ
និងជាមន្ត្រីនាំពាក្យក្រសួងបរិស្ថាន
ទូរស័ព្ទលេខ ០១២ ៩៧១ ២២២
អ៊ីម៉ែល saosopheap@yahoo.com